ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៤០)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ២ ៦១៩ នាក់ នៃរោងចក្រ សហគ្រាស ទាំង២២ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៦០ ០០០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២០ ០០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦០ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។

  សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង២២ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

## ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០

## បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ២២ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 6 |
| 1 | ក្រុមហ៊ុន ជា ជា ហ៊ី ហ្គាម៉ិន (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 2 | ក្រុមហ៊ុន អ៊ីអឹមប៊ី ដែលគូរី (ខេមបូឌា)ខូ.,អិលធីឌី | ភ្នំពេញ |
| 3 | ក្រុមហ៊ុន គ្លូរី នីត វែរ អិលធីឌី | កណ្តាល |
| 4 | ក្រុមហ៊ុន ជីនវីន អ៊ីនដាស្ត្រី ខេមបូឌា ខូអិលធីឌី | កណ្តាល |
| 5 | ក្រុមហ៊ុនឃៃ យ៉ាង ខេមបូឌា ខូអិលធីឌី | កណ្តាល |
| 6 | ក្រុមហ៊ុន ហ្វ្រេសហ្វូល(ខេបូឌា)ថេកស្ទាយ ខូ.អិលធីឌី | តាកែវ |
| ខ. វិស័យទេសចរណ៍ | | 16 |
| 7 | សណ្ឋាគារ ហ្គាឌិន ស៊ីធី ហូថេល | ភ្នំពេញ |
| 8 | ក្រុមហ៊ុន ខាល់ធីស្ប៉ាយស៍(ខេមបូឌា)ខូអិលធីឌី | ភ្នំពេញ |
| 9 | ក្រុមហ៊ុន កាំបូឌីយ៉ាណា អ៊ិនវេស្តមេនធ៍ (ភ្នំពេញ) ភីធីអ៊ី អែលធីឌី | ភ្នំពេញ |
| 10 | សណ្ឋាគារ ភ្នំពេញ អេរ៉ា ហូថេល ឯ.ក | ភ្នំពេញ |
| 11 | ក្រុមហ៊ុន អានឡុង អេហ្សេត អ៊ិវេសមេន | សៀមរាប |
| 12 | ក្រុមហ៊ុន អេច ឌី រ៉ក កាហ្វេ & សប | សៀមរាប |
| 13 | សណ្ឋាគារ អង្គរប៉ារ៉ាឌី | សៀមរាប |
| 14 | ក្រុមហ៊ុន អឹបៅអេស៊ា | សៀមរាប |
| 15 | សណ្ឋាគារប៉ារ៉ាឌីសអង្គរវីឡា | សៀមរាប |
| 16 | ក្រុមហ៊ុន ផ្កាចន្ទន៍ សៀមរាប យ៉ុងឆាង | សៀមរាប |
| 17 | ក្រុមហ៊ុន ម៉េម៉រអង្គរ (ខេមបូឌា) | សៀមរាប |

| ល.រ | ឈ្មោះភោជនីយដ្ឋាន សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 18 | ក្រុមហ៊ុន ខហ្វហ្វី ខនសិប (ខេមបូឌា) លីមីធីត (សាខាខេត្តសៀមរាប) | សៀមរាប |
| 19 | ក្រុមហ៊ុន តារាវង្សី អង្គរ ហូថេល | សៀមរាប |
| 20 | ក្រុមហ៊ុន ត្រេហ្វឹ អូអេស៊ីស | សៀមរាប |
| 21 | ក្រុមហ៊ុន ហ្គោលដេន ទ្រី ព្រីនស៍ ហូថែល និងស្ប៉ា | សៀមរាប |
| 22 | ក្រុមហ៊ុន ដឺ អេវៀរី | សៀមរាប |